**Guilty Plea (GP)**

វាជានីតិវិធីពេញនិយមមួយក្នុងប្រព័ន្ធកំមុនឡ ដែលនៅក្នុងប្រព័ន្ធស៊ីវិលឡ (civil law) គេហៅថា ការទទួលស្គាល់អង្គហេតុ (admission of fact) ឬពាក្យ «ទទួលយកពិរុទ្ធភាព» (admission of guilty) ជាពាក្យកណ្តាលរវាងប្រព័ន្ធទាំងពីរនេះ។

GP ជាយន្តការសម្រួលរវាងរដ្ឋអាជ្ញា និងជនត្រូវចោទ ដោយក្នុងនោះ រដ្ឋអាជ្ញាផ្តល់សម្បទានលើទោស (sentencing concession) ជាថ្នូរនឹងសារភាពទទួលយក (entry plea)។ ខ្លឹមសារនៃការឯកភាពនេះ នឹងត្រូវទទួលយកតាមក្រោយដោយថៅក្រម ហើយដែលតម្រូវឲ្យមានលក្ខខណ្ឌចំនួនបួនៈ ១. វាត្រូវតែធ្វើឡើងដោយស្ម័គ្រចិត្ត។ ២. ត្រូវតែមានការជូនដំណឹងថា ជនត្រូវចោទយល់អំពីប្រភេទចោទប្រកាន់ចំពោះគាត់ និងផលវិបាកនៃ GP។ ៣. ត្រូវតែមានមូលដ្ឋានអង្គហេតុរឹងមាំ សម្រាប់បទល្មើស និងការចូលរួមក្នុងបទល្មើស និងទី៤. មិនត្រូវមានបង្ហាញមូលហេតុដោះសារ (excuse) ដែលនាំឲ្យផ្ទុយនឹងការរទទួលយកពិរុទ្ធភាព។

ភាគីនឹងបង្កើតនូវកិច្ចព្រមព្រៀង (plea agreement) ដែលមិនចងដល់ថៅក្រមទេ។ ថៅក្រមនឹងពិចារណាតាមឆន្ទានុសិទ្ធិលើបញ្ហានេះ ដោយពិចារណានូវកត្តាបន្ថែមទៀត ដូចជាផលប្រយោជន៍របស់ជនរងគ្រោះ (interest of victim) ការគោរពសិទ្ធិជនត្រូវចោទជាដើម។

ថៅក្រមនឹងបដិសេធកិច្ចព្រមព្រៀង ដែលនឹងក្លាយជាគ្មានសុពលភាព (null and void) ប្រសិនបើលក្ខខណ្ឌខាងលើ មិនត្រូវបានបំពេញ។ សំណុំរឿង នឹងត្រូវបានបញ្ជូនទៅជម្រះតាមនីតិវិធីធម្មតាវិញ។

ក្នុងការទទួលយក GP ជនត្រូវចោទ នឹងបោះបង់សិទ្ធិក្នុងដំណើរការក្តីព្រហ្មទណ្ឌ ដូចជាសិទ្ធិទទួលបានសវនាការជាសាធារណៈ (public hearing) សិទ្ធិសន្មតជាមុនថាមិនមានទោស (presumption of innocence) សិទ្ធិរក្សាភាពស្ងៀមស្ងាត់ (right to remain silent) សិទ្ធិមិនឆ្លើយដាក់បន្ទុកខ្លួនឯង (right not to self-incrimination) សិទ្ធិឆ្លើយតទល់ (right to cross examination) ឬសិទ្ធិបង្ហាញភស្តុតាង (right to present evidence) (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 338-339)។